# Living the Lotus 1

2024

Buddhism in Everyday Life

VOL. 220




Rissho Kosei-kai of San Antonio


**Living the Lotus**
**Vol.220 (January 2024)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីស្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីស្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីស្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# ភ្ជួរស្រែបេះដូងដោយវីរិយៈឬសេចក្ដីព្យាយាម

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## 《វីរិយៈឬសេចក្ដីព្យាយាមគឺជាសត្វគោដែលដឹកអីវ៉ាន់……》

សូមជូនពរឆ្នាំថ្មីអ្នកទាំងអស់គ្នា

កំណាព្យ “ រដូវផ្ការីកចូលមកដល់ក្លោងទ្វារផ្ទះទាំងឡាយដែលមានតាំងកូនដើមស្រល់លំអនៅពីមុខ” និពន្ធដោយព្រះគ្រូសៃគ្យោជាកំណាព្យដែលបង្ហាញពីទឹកចិត្តស្រស់ស្រាយនៅពេលដែលរដូវផ្ការីកចូលមកដល់។បច្ចុប្បន្ននេះយើងមិនសូវឃើញមានផ្ទះដែលតាំងកូនដើមស្រល់ពីមុខលំអនៅពេលចូលឆ្នាំថ្មីដូចពីមុនទៀតមែន ក៏ប៉ុន្តែសូមបន់ស្រន់ឱ្យយើងទាំងអស់គ្នាទទួលឆ្នាំថ្មីដោយអារម្មណ៍ស្រស់ស្រាយរីករាយដូចទស្សនីយភាពនៃឆ្នាំថ្មីប្រពៃណីជប៉ុនពីដើមរៀងមក ហើយសូមឱ្យក្នុងមួយឆ្នាំនេះយើងទាំងឡាយ ទាំងអ្នកទាំងអស់គ្នាទាំងអាត្មាភាពមានសេចក្ដីសប្បាយរីករាយ និងសុខភាពល្អ។

និយាយអ៊ីចឹង យើងទាំងឡាយបានរៀនព្រះធម៌របស់ព្រះពុទ្ធហើយយោងទៅតាមការសិក្សារៀនសូត្រនេះយើងចង់កែលំអខ្លួនឱ្យបានទៅជាមនុស្សល្អទោះជាមួយជំហានក្ដី ពីរជំហានក្ដីទៅមុខ។សេចក្ដីប្រាថ្នានេះមិនមែនមិនអាចក្លាយទៅជាការពិតបានទេ ផ្ទុយទៅវិញនៅពេលដែលតាំងចិត្តថា ត្រូវតែរស់ដូចព្រះសម្មាសម្ពុទ្ធដែរ ហើយព្យាយាមដើរតាមសេចក្ដីបង្រៀនប្រៀនប្រដៅរបស់ព្រះអង្គ ជានិច្ចជាកាលទៅយើងនឹងទទួលបាននូវសេចក្ដីសប្បាយរីករាយពីការលូតលាស់និងរីកចំរើនក្នុងភាពជាមនុស្ស។

ក៏ប៉ុន្តែខ្ញុំព្រះករុណាអាត្មាភាពគិតថានៅពេលដែលឮពាក្យថាប្រតិបត្តិមាគ៌ាព្រះពុទ្ធ ឬវីរិយៈ (ព្យាយាម) មនុស្សជាច្រើនច្បាស់ជាមានអារម្មណ៍ថា ត្រូវខិតខំឬធ្វើខ្លួនឱ្យទៅជាមនុស្សអស្ចារ្យទើបបានមិនខានឡើយ។ ក៏ប៉ុន្តែនៅក្នុងគម្ពីរព្រះធម៌ដំបូងសុត្តនិបាត □□□□□□-□□□□□□□ ព្រះសម្មាសម្ពុទ្ធបានសម្ដែងថា៖វីរិយៈឬសេចក្ដីព្យាយាមគឺជាសត្វគោដែលដឹកអីវ៉ាន់នាំទៅកន្លែងសុខស្ងប់។យោងទៅតាមព្រះពុទ្ធដីការបស់ព្រះអង្គយើងមិនទទួលអារម្មណ៍សូម្បីតែបន្តិចក៏គ្មានថាកិច្ចប្រតិបត្តិសេចក្ដីព្យាយាមមានការលំបាកឬក៏ភាពតឹង រ៉ឹងដែរ ផ្ទុយទៅវិញយើងនឹកឃើញ

ដល់រូបភាពសត្វគោដែលកំពុងតែអូសរទេះផ្ទុកអីវ៉ាន់ដើរយឺតៗយ៉ាងស្ងប់ស្ងៀមឬក៏សត្វគោដែលកំពុងតែអូសនង្គ័លយ៉ាងស្ងៀមស្ងាត់ភ្ជួរស្រែ។ ដូច្នេះចូរយើងគិតបែបនេះហើយទៅសន្សឹមៗហើយកុំបីឈប់ភ្ជួរស្រែបេះដូងដោយការសិក្សារៀនសូត្រការប្រៀនប្រដៅរបស់ព្រះពុទ្ធហើយសំខាន់ត្រូវឈានជើងមួយជំហានៗទៅមុខមួយ ៗ។នឹកដល់រឿងនេះក៏រំលឹកឃើញកាលពី២៥ឆ្នាំមុនខ្ញុំព្រះករុណាអាត្មាភាពបានសរសេរសៀវភៅមួយដែលមានចំណងជើងថា" ភ្ជួរស្រែបេះដូង"។

## មិនឱ្យដាច់

កែស្វូសាម៉ាលោកបានមានសង្ឃដីកាយ៉ាងច្បាស់ថា 〈មនុស្សគឺដូចគ្នា〉 · 〈អ្វីៗទាំងអស់គឺតែមួយ〉 ……។នេះគ្មានអ្វីក្រៅពីទស្សនៈឬឧត្តមគតិជាមូលដ្ឋានរបស់ព្រះពុទ្ធសាស នាឡើយ។ ប្រសិនបើយើងភ្ញាក់រលឹកពីចំណុចនេះ ទស្សនៈរបស់យើងក៏ប្រែប្រួល របៀបរស់នៅរបស់យើងក៏នឹងប្រែប្រួលហើយប្រសិនបើនៅក្នុងលោកនេះមនុស្សនាំគ្នាគិតបែបនេះនោះ មនុស្សនឹងចេះស្រឡាញ់គ្នា។នេះហើយជាធម៌ព្រះពុទ្ធ។ខ្ញុំព្រះករុណាអាត្មាភាពអានទៅក៏យល់ថាទោះបីជាក្រុមសាសនាឬនិកា យខុសគ្នាក្តីក៏យើងអាចគិតថា " យើងម្នាក់ៗជាជីវិតមួយដែលស្មើគ្នា មានតម្លៃដូចគ្នា ជាជីវិតដ៏គួរឱ្យដឹងគុណទាំងអស់ជាជីវិតមួយ ជាមិត្ត ជាភឿនដែលបន្តភ្ជាប់គ្នាមួយជួររួមបញ្ចូលគ្នាជារបស់មួយ នៅក្រោមម្លប់ព្រះធម៌របស់ព្រះពុទ្ធឆ្លើយតបទៅនឹងសំណូមពរផ្សេងៗយោងទៅតាមខ្លឹមសារនិងភាពសម្បូរបែបទាំងប្រភេទទាំងទម្រង់។

ព្រះចៅអធិការវត្តអេយហេយជីខាងនិកាយសូតូស្ហ៊ូព្រះគ្រូយ៉ាម៉ាដារេយរីងមានសង្ឃដីកាថា៖ ព្រះគ្រូដូហ្គេងដែលជាព្រះសង្ឃខាងសមា ធិហ្សេងទោះជាព្រះអង្គទតឃើញអ្វីឬឮអ្វីក៏ទ្រង់មានអារម្មណ៍ថាគឺជាខ្លួនព្រះអង្គផ្ទាល់។មនុស្សដែលយើងហៅថា “អ្នកដទៃ” ព្រះអង្គលោកប្រើពាក្យថា“ខ្លួនឯងដទៃ”។ដទៃនោះគឺដទៃហើយក៏ប៉ុន្តែលោកទទួលអារម្មណ៍ថាជា“ខ្លួនរបស់ព្រះអង្គផ្ទាល់”ហើយសេចក្តីសប្បាយ សេចក្តីទុក្ខរបស់អ្នកនោះគឺជាសេចក្តីសប្បាយ សេចក្តីទុក្ខរបស់“ព្រះអង្គផ្ទាល់” (សេចក្តីនេះមានសរសេរនៅក្នុង“មហាកងច័ក្រព្រះធម៌”ទី៣ខណ្ឌទី៣៦) ហើយទ្រង់មានសង្ឃដីកាថានេះគឺជា“ជីវភាពរបស់មនុស្សពិតៗ”។

ប្រាកដណាស់ថានៅក្នុងមាគ៌ាព្រះពុទ្ធសាស នាកិច្ចប្រតិបត្តិដ៏តឹងរ៉ឹងគឺជាកិច្ចប្រតិបត្តិវិរិយៈ (ព្យាយាម) ហើយក៏ប៉ុន្តែខ្ញុំព្រះករុណាអាត្មាភាពយល់ថា នៅក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់យើងនៅពេលដែលយើងត្រូវបានលោភៈឬក៏កំហឹងឬចិត្តច្រណែនមកយាយីតាមតែអស្មិមានៈរបស់ខ្លួនបើយើងអាចរំលឹកឃើញពាក្យថា 〈មនុស្សគឺដូចគ្នា〉 · 〈អ្វីៗទាំងអស់គឺតែមួយ〉 នោះក៏គេហៅថាវិរិយៈឬព្យាយាមបានដែរ។យើងមិនត្រូវឱ្យសេចក្តីព្យាយាមនោះសម្រាក ឬ ដាច់ឡើយត្រូវតែឱ្យបន្តភ្ជាប់រហូត។ទង្វើនេះគឺជាជីវិតដែលសេចក្តីប្រាថ្នារបស់ព្រះសម្មាសម្ពុទ្ធចាក់ឫសនៅក្នុង។ទឹកចិត្តនេះនឹងទ្រទ្រង់ពាក្យសម្តីដ៏ធម្មតានៅក្នុងជីវិតរស់នៅរាល់ថ្ងៃរបស់យើងដោយការបន្តភ្ជួរស្រែបេះដូងហើយប្រកបជីវភាពមួយថ្ងៃៗដោយសុខសប្បាយ ដោយចិត្តកក់ក្តៅ។

《ទស្សនាវត្តីកូសេ》 លេខខែ១ ឆ្នាំ២០២៤



# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**twitter**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp